# ថវិកា២៣៣លានដុល្លារនឹងបែងចែកដល់ថ្នាក់ក្រោមជាតិ

**ឆាយ ច័ន្ទនីដា**

**ភ្នំពេញ:** រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១៤ នឹងបែងចែកថវិកាជាង២៣៣លានដុល្លារ ដែលមានកំណើនជាងឆ្នាំ២០១៣ ដើម្បីឲ្យដល់ថ្នាក់ក្រោមជាតិធ្វើការអភិវឌ្ឍសមត្ថភាព និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។

ក្នុងសិក្ខាសាលាស្ដីពីការធ្វើផែនការសកម្មភាពឆ្នាំ២០១៤ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប ) លោក កែវ បេងវឌ្ឍន៍ អគ្គនាយកហិរញ្ញវត្ថុ និងរដ្ឋបាលមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើបទបង្ហាញថា ថវិកាសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៤ មានមូលនិធិឃុំសង្កាត់ ២៣៧ ២៦៦លានរៀល មូលនិធិក្រុង ស្រុក មាន៦៩ ០៤៤លានរៀល និងថវិការាជធានីខេត្តឆ្នាំ២០១៤ មាន៦៤០ ៨៣៨លានរៀល។ ជាសរុបថវិកាទាំងអស់មានចំនួន៩៤៧ ១៤៨លានរៀល ដែលប្រហែលជាង២៣៣លានដុល្លារអាមេរិក។

លោកថ្លែងថា ថវិកាថ្នាក់ឃុំសង្កាត់មានការកើនឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០២ដែលមានចំនួនជាង៧លានដុល្លារ រហូតមកឆ្នាំ២០១៤មានដល់ទៅជាង៥៨លានដុល្លារអាមេរិក។ លោកថា៖ «កំណើនមូលនិធិឃុំសង្កាត់សម្រាប់ឆ្នាំ២០១៤ មានចំនួន១៣,៨៤ភាគរយ ធៀបនឹងឆ្នាំ២០១៣។ កំណើនមូលនិធិក្រុង មានប្រមាណ១៣,៨៦ភាគរយធៀបនឹង២០១៣។ កំណើនថវិការាជធានីខេត្តឆ្នាំ២០១៤ មានចំនួនប្រមាណ២១,៦៣ភាគរយ ធៀបនឹងឆ្នាំ២០១៣»។

ថវិកាជាតិសម្រាប់ឆ្នាំ២០១៤ ដែលទើបអនុម័តខែមុន មានចំនួន៣៤៥៥លានដុល្លារអាមេរិក។ លោក ង៉ាន់ ចំរើន អនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាននៃ គ.ជ.អ.ប ថ្លែងថា មូលនិធិឃុំសង្កាត់ ក្រុងស្រុក និងថវិការាជធានី ដែលមានកំណើន គឺផ្អែកទៅលើចំណូលថវិកាជាតិប្រចាំឆ្នាំកើន ដែលក្រសួងសេដ្ឋកិច្ចអះអាងថា មានចំនួន៧,៦ភាគរយនៅឆ្នាំ២០១៣។ លោកថា៖ «តាមច្បាប់មូលនិធិឃុំសង្កាត់នឹងកើន២,៨ភាគរយថេររៀងរាល់ឆ្នាំ ដូច្នេះឆ្នាំបន្តបន្ទាប់ថវិកានឹងកើន តែអាស្រ័យលើកំណើនថវិកាជាតិ។ មូលនិធិទាំងអស់គឺដើម្បីលើកកម្ពស់សមត្ថភាព កែទម្រង់រដ្ឋបាលថ្នាក់ក្រោម ក៏ដូចជាអភិវឌ្ឍនៅតាមមូលដ្ឋាន និងធ្វើឲ្យមានអភិបាលកិច្ច»។

> **“ថវិកាឃុំសង្កាត់ ឃើញនៅមានតិចតួចបើធៀបនឹងថវិកាចាយនៅថ្នាក់ជាតិដែលគេចាយធំ**

លោកថា រដ្ឋាភិបាលដែលមានក្រសួងមុខងារសាធារណៈទើបបង្កើតថ្មី នឹងព្យាយាមផ្ដល់អំណាចឲ្យច្រើនទៅរដ្ឋបាលមូលដ្ឋាន ដែលនៅឆ្នាំ២០១៤ នឹងធ្វើការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់ឲ្យថ្នាក់ខេត្តរាជធានីផ្ទាល់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានសិទ្ធិតែងតាំងជ្រើសរើសមន្ត្រីដោយមិនបាច់ឆ្លងក្រសួងមហាផ្ទៃឡើយ «ហើយដែលនេះជាការផ្ដល់អំណាចទៅកាន់ថ្នាក់ក្រោម»។

លោក សន ជ័យ ប្រធានសម្ព័ន្ធគណនេយ្យភាពសង្គមអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ហៅកាត់ ANSA ថ្លែងថា ទោះកំណើនថវិកាឃុំសង្កាត់ ក្រុងស្រុក និងរាជធានីខេត្ត មានការកើន តែហាក់នៅមានកម្រិត។ លោកថា៖ «យើងដឹងថា ក្រុមប្រឹក្សាឃុំសង្កាត់ ឬរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការជាប់ជាមួយតម្រូវការពលរដ្ឋ ហើយរាល់ថ្ងៃថវិកាឃុំសង្កាត់ ឃើញថា នៅមានតិចតួចបើធៀបនឹងថវិកាចាយនៅថ្នាក់ជាតិដែលគេចាយធំ។ យើងចង់បានថវិកាថ្នាក់មូលដ្ឋាននេះឲ្យច្រើន ជាពិសេសផ្ដល់ការពង្រឹងសមត្ថភាពមន្ត្រីឃុំសង្កាត់ឲ្យចេះធ្វើការជាមួយពលរដ្ឋ និងក៏ដូចលើកទឹកចិត្តពលរដ្ឋក្នុងការរួមអភិវឌ្ឍសង្គមតាមបែបប្រជាធិបតេយ្យ»៕ ■